OFFICE OF THE COMPLIANCE ADVISOR/OMBUDSMAN
2121 PENNSYLVANIA AVENUE, NW •WASHINGTON, DC20433, USA
TELEPHONE (202) 458-9452 • FACSIMILE (202) 522-7400
CAO-compliance@ifc.org

# សេចក្តីថ្លែងព័ត៌មាន

## ដំណើរការដោះស្រាយវិវាទ រវាងសហគមន៍មូលដ្ឋាន និងក្រុមហ៊ុន ទាក់ទងនឹងផលប៉ះពាល់នៃចំការកៅស៊ូក្នុងខេត្តរតនៈគិរី

ទីក្រុងវ៉ាស៊ីនតោន ឌីស៊ី ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៥៖ ការិយាល័យភាពអនុលោម ទីប្រឹក្សា ដោះស្រាយវិវាទ (ស៊ីអេអូ) ដែលជាយន្តការគណនេយ្យភាពឯករាជ្យ សម្រាប់សារជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ដែលជាសាខាផ្នែកវិស័យឯកជនរបស់ក្រុមធនាគារពិភពលោក កំពុងដោះស្រាយពាក្យបណ្តឹងមួយ ដែលសហគមន៍មូលដ្ឋានក្នុងខេត្តរតនៈគិរី ប្រទេសកម្ពុជា បានប្តឹងទាក់ទងនឹងក្រុមហ៊ុន ហុងអាញ់យាឡាយ (GAGL) ដែលធ្វើប្រតិបត្តិការចំការកៅស៊ូក្នុងតំបន់នោះ។

យោងតាមឯកសាររបស់សារជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ក្រុមហ៊ុន ហុងអាញ់យាឡាយ គឺជាក្រុមហ៊ុនវិនិយោគរបស់ក្រុមហ៊ុនសហគ្រាសវិនិយោគវៀតណាមចំកាត់ (VEIL ឬ "មូលនិធិ")។ សារជីវកម្មហិរញ្ញវត្ថុអន្តរជាតិ បានវិនិយោគថវិកា១២លានដុល្លាសហរដ្ឋអាមេរិក ដែលថវិកានេះគ្រប់គ្រងដោយក្រុមហ៊ុនគ្រប់គ្រងមូលធនដ្រេហ្គិន ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធមួយរបស់ក្រុមមូលធនដ្រេហ្គិន។

ប្រជាពលរដ្ឋមូលដ្ឋានរងផលប៉ះពាល់ បានដាក់ពាក្យបណ្តឹងក្នុងខែកុម្ភៈ ឆ្នាំ២០១៤ និង បានលើកឡើងនូវការព្រួយបារម្ភនានាទាក់ទងនឹងការបាត់បង់ដីធ្លី និង ផលប៉ះពាល់លើជីវភាពរស់នៅ ក្នុងភូមិចំនួន១៧ ដែលស្ថិតនៅក្បែរកន្លែងប្រតិបត្តិការរបស់ក្រុមហ៊ុនហុងអាញ់យាឡាយ។ ដើមបណ្តឹងបានស្នើសុំឱ្យរក្សាការសម្ងាត់។ ក្នុងខែមេសា ឆ្នាំ២០១៤ អ្នកតំណាងរបស់ សហគមន៍រងផលប៉ះពាល់ និង ក្រុមហ៊ុនហុងអាញ់យាឡាយ បានជ្រើសរើសចូលរួមក្នុងដំណើរការដោះស្រាយវិវាទដែល សម្របសម្រួលដោយការិយាល័យស៊ីអេអូ។

ក្រោយពេលទទួលបានលិខិតគាំទ្រដំណើរការនេះពីក្រសួងមហាផ្ទៃ ក្នុងខែតុលា ឆ្នាំ២០១៤ ការិយាល័យស៊ីអេអូ បានបង្ក លក្ខណៈឱ្យមានការចូលរួមពីភាគីក្នុងការបង្កើតវិធានមូលដ្ឋាន ផ្តល់ការបណ្តុះបណ្តាលអំពីការដោះស្រាយវិវាទ ជូនអ្នកតំណាងសហគមន៍ ទីប្រឹក្សា និង បុគ្គលិកក្រុមហ៊ុន ព្រមទាំងសម្របសម្រួលកិច្ចប្រជុំនៅក្នុងភូមិរងផលប៉ះពាល់ រួមគ្នាជាមួយអង្គការសង្គមស៊ីវិលដែលគាំទ្រសហគមន៍ ដែលនៅក្នុងកិច្ចប្រជុំទាំងនោះ សហគមន៍រងផលប៉ះពាល់បានអនុម័តគាំទ្រចំពោះអ្នកតំណាងរបស់ពួកគេ។

ដើម្បីបន្តជូនដំណឹងដល់រាជរដ្ឋាភិបាលកម្ពុជាអំពីជំនួយរបស់ការិយាល័យស៊ីអេអូចំពោះភាគី ក្នុងការបន្តដោះស្រាយពាក្យបណ្តឹង ព្រមទាំងដើម្បីទទួលបានកិច្ចគាំទ្រ និងកិច្ចសហប្រតិបត្តិការពីរាជរដ្ឋាភិបាល ការិយាល័យស៊ីអេអូ បានជួបជាមួយអ្នកតំណាង

មកពីក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងមហាផ្ទៃ និង មន្ទីរពាក់ព័ន្ធ រាប់បញ្ចូលទាំងសាលាខេត្តរតនៈគិរី និង អាជ្ញាធរមូលដ្ឋានកម្រិតថ្នាក់ស្រុក ឃុំ និង ភូមិ។
ដំណើរការដោះស្រាយវិវាទរបស់ការិយាល័យស៊ីអេអូ កំពុងបន្ត។ នៅថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៥ ភាគីបានអនុម័តទៅលើកិច្ចព្រមព្រៀងសម្របសម្រួលមួយ ព្រមទាំងបានឯកភាពចេញសេចក្តីថ្លែងការណ៍រួមមួយដើម្បីធ្វើបច្ចុប្បន្នភាពដល់សាធារជនអំពីការងាររបស់ពួកគេ។ អាស្រ័យដោយបទដ្ឋាននៃការអនុវត្តន៍ការងារសម្រុះសម្រួល និង ដោយមានការព្រមព្រៀងពីភាគី ខ្លឹមសារលម្អិតនៃកិច្ចប្រជុំត្រូវបានរក្សាជាការសម្ងាត់។

សេចក្តីលម្អិតបន្ថែមអំពីករណីនេះអាចរកមើលបាននៅឯ៖ www.cao-ombudsman.org

**ជនបង្គោលទំនាក់ទំនងរបស់ការិយាល័យស៊ីអេអូ នៅទីក្រុងវ៉ាស៊ីនតោន ឌីស៊ី៖**

អេមីលី ហ័រហ្គិន
ទូរស័ព្ទ៖ +1.202.473.8353
អ៊ីមែល៖ ehorgan@worldbankgroup.org

---

**អំពីការិយាល័យស៊ីអេអូ៖**

*ការិយាល័យភាពអនុលោម ទីប្រឹក្សា ដោះស្រាយវិវាទ (ការិយាល័យស៊ីអេអូ) គឺជាយន្តការឧបាស្រ័យ និងគណនេយ្យភាពឯករាជ្យរបស់សារជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (អាយអែហ្វស៊ី) និងទីភ្នាក់ងារធានាការវិនិយោគពហុភាគី (មីហ្គា) ដែលជាសាខាផ្នែក វិស័យឯកជនផ្តល់កម្ចី និងធានារ៉ាប់រង របស់ក្រុមធនាគារពិភពលោក។ បង្កើតឡើងក្នុងឆ្នាំ១៩៩៩ ការិយាល័យស៊ីអេអូ រាយការណ៍ដោយផ្ទាល់ជូនប្រធានក្រុមធនាគារពិភពលោក។ ការិយាល័យនេះមានអាណត្តិការងារជួយដោះស្រាយពាក្យបណ្តឹង របស់ប្រជាពលរដ្ឋរងផលប៉ះពាល់ពីគម្រោងរបស់ អាយអែហ្វស៊ី/មីហ្គា ក្នុងលក្ខណៈមួយប្រកបដោយភាពយុត្តិធម៌ មិនលំអៀង និង ប្រកបដោយភាពស្ថាបនា ក្នុងគោលដៅរួម សំដៅលើកកម្ពស់លទ្ធផលផ្នែកសង្គម និងបរិស្ថានជាក់ស្តែងនៅមូលដ្ឋាន និង ជម្រុញឱ្យ អាយអែហ្វស៊ី និងមីហ្គា មានគណនេយ្យភាពសាធារណៈកាន់តែប្រសើរឡើងជាលំដាប់។*